ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ...០៤២...ស.ន.ប

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ
# នៃក្រសួងសុខាភិបាល

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៥/០០៧ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ ប្រកាសឲ្យប្រើប្រាស់ច្បាប់ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៥/១១៤១ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

-បានឃើញអនុក្រឹត្យលេខ ៦៧អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញសារាចរលេខ០២សរចុះថ្ងៃទី១៤ខែមករាឆ្នាំ២០២០ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងក្រសួងស្ថាប័ន

-បានឃើញលិខិតលេខ ០១៤ រប.គ.ជ.គ.ម ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ស្តីពីការរៀបចំបង្កើតលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងក្រសួង ស្ថាប័ន

-យោងតាមតម្រូវការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ ស្ថិតនៅនាយកដ្ឋានការពារសុខភាព ទីស្តីការក្រសួងសុខាភិបាលមានសមាសភាពដូចខាងក្រោម៖

១-ឯកឧត្តមវេជ្ជបណ្ឌិត **សាន់ សាច់អី** រដ្ឋលេខាធិការក្រសួងសុខាភិបាល ប្រធាន

២-ឯកឧត្តម **សុខ សុគន្ធ** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល អនុប្រធាន

៣-ឯកឧត្តម **ស៊ិក ប៊ុណ្ណា** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល អនុប្រធាន

៤-ឯកឧត្តម **ហុក គឹមចេង** អគ្គនាយកបច្ចេកទេសសុខាភិបាល អនុប្រធាន

៥-ឯកឧត្តម **សុខ សំអេង** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អនុប្រធាន

៦-ឯកឧត្តម **ឈាង រ៉ា** អគ្គនាយកមន្ទីរពេទ្យកាល់ម៉ែត សមាជិក

៧-លោកវេជ្ជបណ្ឌិត **ឆាង តារិទ្ធ** អគ្គនាយករងបច្ចេកទេសសុខាភិបាល មន្ត្រីបង្គោល

៨-លោកវេជ្ជបណ្ឌិត **ខ៊ុំ ភាង** អគ្គាធិការរងក្រសួងសុខាភិបាល សមាជិក

៩-លោកវេជ្ជបណ្ឌិត **សុខ ស្រ៊ុន** ប្រធាននាយកដ្ឋានមន្ទីរពេទ្យ សមាជិក

១០-លោកវេជ្ជបណ្ឌិត **គុល ហៅរ៉ូ** ប្រធាននាយកដ្ឋានការពារសុខភាព សមាជិក

១១-លោកវេជ្ជបណ្ឌិត **លូ លីឃាង** នាយកមន្ទីរពេទ្យព្រះអង្គឌួង សមាជិក

១២-លោកវេជ្ជបណ្ឌិត **ទី ម៉េង** នាយកមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត សមាជិក

១៣-លោកវេជ្ជបណ្ឌិត **ញ៉ឹប អង្គាបុស្ស** នាយកមន្ទីរពេទ្យកុមារជាតិ សមាជិក

១៤-លោកវេជ្ជបណ្ឌិត **តាន់ សុគុន** នាយកមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ សមាជិក

១៥-លោក **គីម ណារ៉េន** អនុប្រធាននាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ សមាជិក

១៦-លោកស្រីវេជ្ជបណ្ឌិត **ឡាក់ មួយស៊ាង** អនុប្រធាននាយកដ្ឋានការពារសុខភាព មន្ត្រីបង្គោល។

**ប្រការ ២.-**

លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយក្រសួងសុខាភិបាលមានភារកិច្ចដូចខាងក្រោម ៖

- រៀបចំនីតិវិធីនិងគោលការណ៍សម្រាប់អនុវត្តន៍ក្របខណ្ឌការងារ គ្រប់គ្រងគ្រោះមហន្តរាយ ក្នុងក្រសួងសុខាភិបាល សម្រាប់មុនពេល ក្នុងពេលនិងក្រោយពេល គ្រោះមហន្តរាយ
- សម្របសម្រួលការបញ្ជ្រាបការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ទៅក្នុងផែនការរយៈពេលវែង ផែនការប្រចាំឆ្នាំ និងផែនការសកម្មភាពការងារទៅក្នុងអង្គភាពពាក់ព័ន្ធ ក្រោមចំណុះក្រសួងសុខាភិបាល
- រៀបចំផែនការត្រៀមបម្រុងសម្រាប់ការឆ្លើយតប សង្គ្រោះបន្ទាន់និងស្តារឡើងវិញ
- សម្របសម្រួលឲ្យមានការលើកគម្រោងថវិកា និងគាំទ្រថវិកាដល់ការអនុវត្តផែនការគ្រប់គ្រងគ្រោះមហន្តរាយ ដែលបានបញ្ជ្រាបក្នុងក្រសួងសុខាភិបាល
- ចូលរួមរៀបចំផែនការសកម្មភាពជាតិ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដើម្បីបន្សីសកម្មភាពការគ្រប់គ្រងគ្រោះមហន្តរាយរបស់ក្រសួងសុខាភិបាល ទៅក្នុងផែនការសកម្មភាពជាតិ
- ចូលរួមសម្របសម្រួលនិងធ្វើប្រតិបត្តិការឆ្លើយតបគ្រោះអាសន្ននិងការស្តារឡើងវិញក្រោយគ្រោះមហន្តរាយ
- ចូលរួមជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងការបណ្តុះបណ្តាលលើការគ្រប់គ្រងគ្រោះមហន្តរាយ អនុវត្តការប៉ាន់ប្រមាណការខូចខាត បាត់បង់ និងសេចក្តីត្រូវការពីគ្រោះមហន្តរាយក្នុងវិស័យសុខាភិបាល និងតាមដានត្រួតពិនិត្យ វាយតម្លៃលទ្ធផលដំណើរការរបស់អង្គភាពក្រោមឱវាទ

- សិក្សាស្រាវជ្រាវមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិ ឬមនុស្សនិងហានិភ័យផ្សេងៗ ដើម្បីដាក់ចេញវិធានការត្រៀមបង្ការ និងផ្តល់គោលការណ៍ណែនាំនៅតាមអង្គភាពក្រោមឱវាទ

-ផ្តល់ព័ត៌មាននិងរាយការណ៍ពីសភាពការណ៍និងសកម្មភាពការងារគ្រប់គ្រងគ្រោះមហន្តរាយរបស់ក្រសួងសុខាភិបាលជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

**ប្រការ ៣.-**

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល និងមន្ត្រីរាជការដែលមាននាមក្នុងប្រការ ១ ត្រូវទទួលភារៈអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃចន្ទ ១១រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែមករា ឆ្នាំ២០២០

**កន្លែងទទួល:**

- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- គ្រប់អង្គភាពពាក់ព័ន្ធ
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ

Mam Bunheng

**ម៉ម ប៊ុនហេង**